# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៥ សរណន

# សារាចរណែនាំ

## ស្តីពី

## ការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍បទបញ្ជា លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

**** + ****

ក្នុងទិសដៅពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្រោមក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន ខេត្ត-ក្រុង និង ឃុំ- សង្កាត់ ឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលដាក់ចេញនូវបទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ។ ដោយពិនិត្យឃើញសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការជម្រុញលើកទឹកចិត្តការអនុវត្តន៍គម្រោងវិនិយោគនានា ពិសេសក្នុងវិស័យកសិកម្ម ដែលត្រូវការដោយខ្វះមិនបាននូវសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់ដែលមានការពាក់ព័ន្ធ ពិសេសគឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា និង អាជ្ញាធរខេត្ត- ក្រុង ដូចតទៅ :

ទី១- ដោយអនុវត្តតាមបទបញ្ជា លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្នុងរយៈពេលរង់ចាំអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលអនុញ្ញាតឱ្យផ្តល់សម្បទានដីសេដ្ឋកិច្ច ក្នុងទំហំមិនលើស ១០.០០០ ហត ស្របតាមបទប្បញ្ញត្តិនៃច្បាប់ភូមិបាល ជូនដល់វិនិយោគិនដែលបានចំណាយទុនរបស់ខ្លួនរួចហើយ ក្នុងការស្វែងរកទីតាំងផ្ទៃដីវិនិយោគ និង ក្នុងការរៀបចំការសិក្សាអំពីសមិទ្ធិលទ្ធភាពនៃការអនុវត្តន៍គម្រោង ហើយបានដាក់ពាក្យសុំវិនិយោគ និង ការសិក្សាទាំងអស់នេះជូនក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់ រាជរដ្ឋាភិបាល ពិនិត្យ និង សម្រេច តាមនីតិវិធីជាធរមាន ។

ទី២- ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចជូនដល់វិនិយោគិនមានលក្ខណៈគ្រប់គ្រាន់ ដូចមានចែងក្នុងចំណុចទី ១ ខាងលើ ក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល និង វិនិយោគិនដែលមានការពាក់ព័ន្ធត្រូវគោរពដាច់ខាតតាមល័ក្ខខ័ណ្ឌបួនយ៉ាង ដូចខាងក្រោម :

(១)- ផ្ទៃដីសម្បទានដែលត្រូវប្រគល់ជូននោះ មិនត្រូវមានការប៉ះពាល់ដល់កម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសមូហភាពរបស់ប្រជាជននៅក្នុងតំបន់នៃគម្រោងវិនិយោគនោះឡើយ ។ ដើម្បីគោលដៅនេះ ផ្ទៃដីសម្បទានដែលត្រូវប្រគល់ជូននោះ ត្រូវតែបានធ្វើការចុះបញ្ជីត្រឹមត្រូវជាមុនសិន ស្របតាមអនុក្រឹត្យ លេខ ៤៦ អនក្រ. បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ឬ អនុក្រឹត្យលេខ ៤៨ អនក្រ. បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។

(២)- ត្រូវមានរៀបចំផ្ទៃដីត្រៀមបម្រុងសម្រាប់ដោះស្រាយកំណើនប្រជាជន នៅក្នុងរយៈពេលវែងខាងមុខ ។

(៣)- ត្រូវមានការធានាឱ្យប្រជាជននៅក្នុងតំបន់នៃគម្រោងវិនិយោគ អាចទទួលបាននូវផល-ប្រយោជន៍សមរម្យពីគម្រោងវិនិយោគនេះ ដូចជា ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព និងកាលានុវត្តភាពការងារដែលផ្សារភ្ជាប់នឹងគម្រោងវិនិយោគ រាប់ទាំងសមាហរណកម្មផលិតកម្មរបស់គ្រួសារកសិករជាមួយនឹងគម្រោងវិនិយោគនេះផងដែរ ។

(៤)- នៅក្នុងកិច្ចសន្យាសម្បទាន ត្រូវមានប្រការចែងពីល័ក្ខខ័ណ្ឌនៃការបង្អាកការអនុវត្តន៍គម្រោងវិនិយោគ នៅតាមទីតាំងផ្ទៃដីណាដែលមានទំនាស់អំពីកម្មសិទ្ធិជាមួយប្រជាជន រហូតដល់មានការដោះស្រាយរួចរាល់ត្រឹមត្រូវ ស្របតាមនីតិវិធីច្បាប់ជាធរមាន ។

គ្រប់ក្រសួង ស្ថាប័ន និង ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តតាមស្មារតី និង ខ្លឹមសារនៃសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ- កាលប្បវត្តិ